អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៩

# សេចក្ដីប្រកាសព័ត៌មាន

## សវនាការជំនុំជម្រះក្ដីឌុចមានអ្នកទស្សនាជាង ១២០០០ នាក់

នាថ្ងៃពុធ ទី២២ ខែកក្កដា ឆ្នាំ២០០៩នេះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានទទួលសាធារណៈជនទី ១២០០០ (មួយម៉ឺនពីរពាន់) ដែលបានចូលមកទស្សនាដំណើរការជំនុំជម្រះក្ដីលេខ០០១ ប្រឆាំងនឹងជនជាប់ចោទកាំង ហ្គេកអ៊ាវ ហៅឌុច គិតចាប់ពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩។

ក្នុងរយៈកាលប៉ុន្មានខែកន្លងមកនេះ ផ្នែកកិច្ចការសាធារណៈបានខិតខំពង្រឹងលទ្ធភាពការងាររបស់ខ្លួនលើផ្នែកកិច្ចការផ្សព្វផ្សាយ និងការចូលរួមរបស់សាធារណៈជននៅតុលាការនេះ។ ដោយសារការកំណត់គោលដៅផ្សព្វផ្សាយដ៏មានប្រសិទ្ធិភាពតាមរយៈវិទ្យុ តុលាការអាចមានលទ្ធភាពយ៉ាងទូលំទូលាយក្នុងការផ្ដល់ព័ត៌មានដល់ប្រជាពលរដ្ឋនានាអំពីមធ្យោបាយក្នុងការចូលរួមសវនាការ។ អ.វ.ត.ក បាននិងកំពុងផ្ដល់សេវាកម្មដឹកជញ្ជូនតាមរថយន្តក្រុងពីតុលាការទៅកាន់ខេត្តក្រុងនានាសម្រាប់ក្រុមសាធារណៈជនចាប់ពី៣០នាក់ឡើងដែលមានបំណងចង់ចូលរួមក្នុងដំណើរការសវនាការរបស់ឌុចនេះ។

ក្នុងរយៈពេលបួនខែនៃសវនាការរបស់ឌុច មានប្រជាពលរដ្ឋជាច្រើនមានចំណាប់អារម្មណ៍ទស្សនាដំណើរការជំនុំជម្រះក្ដី ឌុច ដោយផ្ទាល់ និងដោយប្រយោល។ សម្រាប់រយៈពេលពីរសប្ដាហ៍ខាងមុខទៀតនេះ សេវាកម្មរថយន្តក្រុងត្រូវបានរៀបចំសម្រាប់ដឹកនាំប្រជាពលរដ្ឋជាង ១០០០ (មួយពាន់) នាក់ឲ្យមកទស្សនាដំណើរការសវនាការ។ តំណាងប្រជាពលរដ្ឋនៅតាមភូមិ និងសហគមន៍ ដែលមានបំណងចង់ចូលរួមក្នុងដំណើរការសវនាការ អាចទាក់ទងលោក ឌឹម សុវណ្ណារុំ មន្ត្រីទទួលបន្ទុកព័ត៌មាន

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

តាមរយៈទូរស័ព្ទលេខ ០១២ ៤៨៨ ០៩៤ ឬលោក ជីន ហែមវិចិត្រ ជំនួយការផ្នែកផ្សព្វផ្សាយ ទូរស័ព្ទលេខ ០១២ ៦៩៦ ២២០។

គិតពីថ្ងៃចាប់ផ្តើមសវនាការនាថ្ងៃទី៣០ ខែមីនា រហូតមកដល់ថ្ងៃអង្គារ ទី២១ ខែកក្កដា ឆ្នាំ២០០៩ នេះមានសាធារណៈជនចំនួន **១១ ៩៩០** (មួយម៉ឺនមួយពាន់ប្រាំបួនរយកៅសិប) នាក់បានចូលរួមសវនាការរបស់ឌុច។ សម្រាប់ចំនួនតួលេខនេះគឺគិតជាមធ្យមមានអ្នកទស្សនា២៤៩ នាក់ក្នុងមួយថ្ងៃ។

| **កាលបរិច្ឆេទនៃសវនាការ (គិតជាសប្តាហ៍)** | **ចំនួនអ្នកចូលទស្សនា (ប្រចាំសប្តាហ៍)** |
|---|---:|
| 30/03/09 - 01/04/09 | 1176 |
| 06/04/09 - 09/04/09 | 623 |
| 20/04/09 - 23/04/09 | 642 |
| 27/04/09 - 30/04/09 | 742 |
| 18/05/09 - 21/05/09 | 575 |
| 25/05/09 - 28/05/09 | 560 |
| 08/06/09 - 10/06/09 | 415 |
| 15/06/09 - 170/6/09 | 621 |
| 22/06/09 - 25/06/09 | 860 |
| 29/06/09 - 02/07/09 | 1899 |
| 06/07/09 - 09/07/09 | 1553 |
| 13/07/09 - 16/07/09 | 1504 |
| 20/07/09 - 21/07/09 | 820 |
| | |
| ចំនួនសរុបរួមគិតត្រឹមថ្ងៃអង្គារ ទី២១ ខែកក្កដា ឆ្នាំ២០០៩ | 11990 |

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌដង្កោ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh

រូបភាពស្តីអំពីដំណើរការសវនាការនាថ្ងៃនេះ អាចស្វែងរកបាននៅក្នុងគេហទំព័រខាងក្រោមនេះ៖
http://www.flickr.com/photos/krtribunal/sets/72157621772525656/

**សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង**

លោករាជ សម្បត្តិ
ប្រធានផ្នែកកិច្ចការសាធារណៈ
ទូរស័ព្ទចល័តលេខ +855 (0) 12 488 156
សារអេឡិចត្រូនិច reach.sambath@eccc.gov.kh

លោកឌឹម សុវណ្ណារ៉ុំ
មន្ត្រីទទួលបន្ទុកការងារព័ត៌មាន
ទូរស័ព្ទចល័តលេខ +855 (0) 12 488 094
សារអេឡិចត្រូនិច dim.sovannarom@eccc.gov.kh

លោកឡាស អូលសិន
មន្ត្រីទទួលផ្នែកទំនាក់ទំនងផ្លូវច្បាប់
ទូរស័ព្ទចល័តលេខ +855 (0) 12 488 023
ទូរស័ព្ទលេខ +855 (0) 23 219 814 លេខបន្ត 6169
សារអេឡិចត្រូនិច olsen@un.org